# សេចក្តីថ្លែងការណ៍រួម

## នៅថ្ងៃគម្រប់រយៈពេលមួយឆ្នាំនៃការឃុំខ្លួនយ៉ាងអយុត្តិធម៌លើអ្នកស្រី ទេព វន្នី ដែលជាសកម្មជនដីធ្លី និងអ្នកការពារសិទ្ធិមនុស្ស សង្គមស៊ីវិលស្នើឱ្យដោះលែងអ្នកស្រីឱ្យមានសេរីភាពវិញ

## #ដោះលែងទេពវន្នី

## រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៧

អ្នកស្រី ទេព វន្នី ដែលជាសកម្មជនដីធ្លី និងអ្នកការពារសិទ្ធិមនុស្សម្នាក់ក្នុងចំណោមអ្នកការពារសិទ្ធិមនុស្សលេចធ្លោជាច្រើនផ្សេងទៀតនៅកម្ពុជា នឹងត្រូវជាប់ក្នុងពន្ធនាគារអស់រយៈពេល ១ ឆ្នាំ នៅថ្ងៃទី១៥ ខែសីហា ដោយសារការការពារសហគមន៍ និងការអនុវត្តសិទ្ធិមនុស្សរបស់អ្នកស្រី។ យើងខ្ញុំ ដែលអង្គការសង្គមស៊ីវិលមានរាយនាមខាងក្រោម ខកចិត្តចំពោះការបន្តឃុំខ្លួនរបស់អ្នកស្រី។ យើងខ្ញុំសូមស្នើឱ្យអាជ្ញាធរបដិសេធសេចក្តីសម្រេចផ្តន្ទាទោសលើអ្នកស្រី ព្រមទាំងទម្លាក់ចោលរាល់បទចោទដែលមានចរិតលក្ខណៈនយោបាយ និងពុំមានភស្តុតាងជាក់លាក់ណាមួយ ដែលកើតមានជាបន្តបន្ទាប់លើអ្នកស្រី និងស្នើឱ្យដោះលែងអ្នកស្រីឱ្យមានសេរីភាពវិញ។

អ្នកស្រី ទេព វន្នី បានប្រឹងប្រែងជាខ្លាំងដោយគ្មានការនឿយហត់ដើម្បីការពារសិទ្ធិរបស់សមាជិកសហគមន៍បឹងកក់ បន្ទាប់ពីការបណ្តេញប្រជាសហគមន៍ទាំងនោះចេញពីផ្ទះសម្បែងរបស់ពួកគេដោយបង្ខំនៅក្នុងរាជធានីភ្នំពេញ។ នាពេលថ្មីៗនេះ អ្នកស្រីបានដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំយុទ្ធនាការ ដែលហៅថា 'ថ្ងៃចន្ទពណ៌ខ្មៅ' ដែលតវ៉ាទៅលើការឃុំខ្លួនបណ្តោះអាសន្នតាមអំពើចិត្តទៅលើអ្នកការពារសិទ្ធិមនុស្សទាំង៥នាក់ រួមមាន អ្នកស្រី លឹម មុន្នី លោក នី សុខា លោក យី សុខសាន្ត លោក ណៃ វង់ដា និងលោក នី ចរិយា (ដែលត្រូវបានឃុំខ្លួននាពេលនោះ) ។ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ បន្ទាប់ពីការចាប់ខ្លួនអ្នកស្រីនៅពេលកំពុងតវ៉ាទាមទារឱ្យមានការដោះលែងអ្នកទាំង៥ អ្នកស្រី ត្រូវបានសាលាដំបូងរាជធានីភ្នំពេញផ្តន្ទាទោសពីបទ 'ប្រមាថអ្នករាជការសាធារណៈ' និងទទួលទោសជាប់ពន្ធនាគាររយៈពេលប្រាំមួយថ្ងៃ។ ប៉ុន្តែ ជាជាងការដោះលែងអ្នកស្រីបន្ទាប់ពីបានអនុវត្តទោសរបស់ខ្លួនរួច អាជ្ញាធរបានសើរើ និងដំណើរការនីតិវិធីឡើងវិញលើបទចោទដែលពុំមានចំណាត់ការយូរមកហើយតាំងពីការតវ៉ាអហិង្សាមួយក្នុងឆ្នាំ២០១៣ ហើយបានបន្តឃុំខ្លួនអ្នកស្រីទុកក្នុងពន្ធនាគារ។

អ្នកស្រី ទេព វន្នី មានប្រសាសន៍ថា *"ទង្វើរបស់អាជ្ញាធរដែលប្រើប្រាស់តុលាការដើម្បីបន្តឃុំខ្លួនខ្ញុំនេះ គឺជាចេតនាយ៉ាងច្បាស់ថា អាជ្ញាធរចង់បំបិទសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់ខ្ញុំ និងបំបាក់ស្មារតីខ្ញុំ។ ពួកគេចង់បញ្ឈប់ខ្ញុំកុំឲ្យធ្វើការតស៊ូមតិទាមទារដំណោះស្រាយជូនពលរដ្ឋបឹងកក់ដែលនៅសេសសល់ និងតស៊ូមតិក្នុងយុទ្ធនាការផ្សេងទៀតដើម្បីទាមទារយុត្តិធម៌នៅក្នុងសង្គមរបស់យើង។"*

នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ អ្នកស្រី ទេព វន្នី ជាមួយនឹងសកម្មជនបឹងកក់ពីរនាក់ផ្សេងទៀត ត្រូវបានសាលាដំបូងរាជធានីភ្នំពេញកាត់ទោសឱ្យជាប់ពន្ធនាគារម្នាក់ៗប្រាំមួយខែពីបទ ‘ប្រមាថ និងបទប្រឆាំងនឹងអ្នករាជការសាធារណៈមានស្ថានទម្ងន់ទោស’ ដែលជាករណីសើរើឡើងវិញ ទាក់ទងទៅនឹងការតវ៉ាដោយសន្តិវិធីមួយក្នុងឆ្នាំ២០១១ ដោយទាមទារឲ្យមានដំណោះស្រាយក្នុងទំនាស់ដីធ្លីនៅតំបន់បឹងកក់ បើទោះជាគ្មានភស្តុតាងដាក់បន្ទុកជាក់លាក់ណាមួយក្តី។ ការកាត់ទោសនេះ ត្រូវបានតម្កល់ដោយសាលាឧទ្ធរណ៍ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧។ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧ បន្ទាប់ពីដំណើរការនីតិវិធីដែលពុំបានអនុលោមតាមបទដ្ឋានការជំនុំជម្រះដោយយុត្តិធម៌[1] នោះមក អ្នកស្រី ទេព វន្នី ត្រូវបានសាលាដំបូងរាជធានីភ្នំពេញកាត់ទោសពីបទ ‘អំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស’ នឹងត្រូវបានដាក់ពន្ធនាគាររយៈពេល ៣០ ខែ បន្ថែមទៀត និងពិន័យជាប្រាក់ចំនួនជាង ១៤ លានរៀល (ប្រមាណ ៣.៥០០ ដុល្លារអាមេរិក ឬ ស្មើនឹងចំនួនពីរដងនៃប្រាក់ឈ្នួលអប្បបរមាប្រចាំឆ្នាំនៅកម្ពុជា) ដោយសារតែបានចូលរួមតវ៉ាដោយសន្តិវិធីក្នុងការក្នុងបាតុកម្ម អំពាវនាវឱ្យដោះលែងអ្នកស្រី យ៉ោម បុប្ផា ដែលជាសកម្មជនដូចគ្នា កាលពីឆ្នាំ២០១៣នោះ។

ខណៈដែលអ្នកការពារសិទ្ធិមនុស្សទាំង៥ ត្រូវបានដោះលែងឱ្យស្ថិតនៅក្រៅឃុំនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ បន្ទាប់ពីបានចំណាយពេលចំនួន ៤២៧ ថ្ងៃនៃការឃុំខ្លួនតាមអំពើចិត្ត[2] អ្នកស្រី ទេព វន្នី នៅតែស្ថិតនៅក្នុងពន្ធនាគារនៅឡើយ។ បច្ចុប្បន្ននេះ អ្នកស្រីកំពុងរង់ចាំការជំនុំជម្រះ ក្នុងបទចោទប្រកាន់ទីបីដែលត្រូវបានសើរើពីបទ ‘ជេរប្រមាថជាសាធារណៈ’ និងបទ ‘គំរាមសម្លាប់’ ដែលបានប្តឹងដោយសមាជិកម្នាក់ទៀតក្នុងសហគមន៍បឹងកក់ផ្សេងទៀត ថ្វីបើដើមបណ្តឹងបានដកពាក្យបណ្តឹងទៅហើយនោះ។[3] នៅថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០១៧ សាលាឧទ្ធរណ៍រាជធានីភ្នំពេញ បានតម្កល់ការផ្តន្ទាទោសរបស់អ្នកស្រី ដែលត្រូវបានសាលាដំបូងរាជធានីភ្នំពេញប្រកាសកាលពីខែកុម្ភៈ ឆ្នាំ២០១៧។

អ្នកការពារសិទ្ធិមនុស្ស ក៏ដូចជាបុគ្គលដទៃដែរ ដែលត្រូវទទួលបានសិទ្ធិ និងសេរីភាពជាមូលដ្ឋានទាំងអស់ ដែលត្រូវបានធានាដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិនានា និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ សិទ្ធិនេះ រួមមាន សិទ្ធិសេរីភាពខាងការបញ្ចេញមតិ ការប្រមូលផ្តុំដោយសន្តិវិធី និងសមាគម ដែលធានាដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាជារដ្ឋភាគី។ សេចក្តីប្រកាសស្តីពីអ្នកការពារ

---

[1] សេចក្តីថ្លែងការណ៍រួមរបស់ក្រុមអង្គការសង្គមស៊ីវិល “អ្នកស្រី ទេព វន្នី ត្រូវបានផ្តន្ទាទោសម្តងទៀត ខណៈដែលក្រុមសន្តិសុខ បានប្រើប្រាស់អំពើហិង្សាទៅលើអ្នកគាំទ្រអ្នកស្រី” (ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧) http://bit.ly/2ts0bfa

[2] សេចក្តីថ្លែងការណ៍របស់យុទ្ធនាការ #ដោះលែងអ្នកទាំង៥ ស្វាគមន៍ការដោះលែងពួកគេ និងស្នើឱ្យទម្លាក់ចោលការចោទប្រកាន់ទាំងអស់ (ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧) http://bit.ly/2thSwjq

[3] សេចក្តីថ្លែងការណ៍រួម “កម្ពុជា ៖ ទម្លាក់បទចោទប្រកាន់ទៅលើអ្នកការពារសិទ្ធិដីធ្លី” (ថ្ងៃទី១៤ ខែកក្កដា ឆ្នា២០១៧) http://bit.ly/2uzdXgb

សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ[4] បញ្ជាក់យ៉ាងច្បាស់បន្ថែមពីសិទ្ធិក្នុងការលើកកម្ពស់ និងការប្រឹងប្រែងដើម្បីការការពារ និងការទទួលស្គាល់សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ព្រមទាំងជាតួនាទីរបស់រដ្ឋទាំងអស់ដើម្បីអនុញ្ញាតឲ្យអ្នកការពារសិទ្ធិមនុស្សទាំងនោះ ធ្វើការដោយសន្តិវិធី និងមានសុវត្ថិភាព និងដើម្បីការពារពួកគេពីការចាប់ខ្លួន អំពើហិង្សា ការគំរាមកំហែង ការព្យាបាទ និងការរើសអើងណាមួយ។ ក្នុងឆ្នាំ២០១៣ មហាសន្និបាតអង្គការសហប្រជាជាតិបានទទួលស្គាល់យ៉ាងច្បាស់លាស់ពីគុណតម្លៃនៃការងាររបស់ស្ត្រីការពារសិទ្ធិមនុស្ស និងការរើសអើង ហើយនិងអំពើហិង្សាដែលមានលក្ខណៈជាប្រព័ន្ធ និងរចនាសម្ព័ន្ធដែលពួកគេប្រឈមព្រមទាំងបានអំពាវនាវដល់រដ្ឋនានាធានាឱ្យស្ត្រីអាចបំពេញតួនាទីសំខាន់របស់ខ្លួន។[5]

អ្នកការពារសិទ្ធិមនុស្សជារឿយៗ ប្រឈមទៅនឹងការយាយីតាមរយៈការប្រើប្រាស់ប្រព័ន្ធតុលាការនៅកម្ពុជា។ ក្នុងចំណោមនោះ វិធីសាស្ត្រដែលច្រើនប្រើជាទូទៅមួយ គឺការអនុវត្តការព្យួរទោស និងការសើរើពីបទចោទដែលឥតចាត់ការយូរមកហើយតាមអំពើចិត្ត ដែលត្រូវបានប្រើប្រាស់ដើម្បីបំភិតបំភ័យដល់អ្នកការពារសិទ្ធិមនុស្ស និងរារាំងពួកគេកុំឲ្យអនុវត្តសកម្មភាពផ្សេងៗនាពេលអនាគត។ ការឃុំខ្លួននាពេលបច្ចុប្បន្នទៅលើអ្នកស្រី ទេព វន្នី គឺហាក់ដូចជាសកម្មភាពជាបន្តបន្ទាប់នៃការយាយីក្នុងគោលបំណងបំបិទសំឡេងអ្នកស្រី។ វិធានការនេះរួមចំណែកបង្កើតបានជាបរិយាកាសភ័យខ្លាចដល់អ្នកការពារសិទ្ធិមនុស្ស និងបុគ្គលដទៃទៀតនៅប្រទេសកម្ពុជា។ ជាលទ្ធផលនៃការដាក់ពន្ធនាគារ អ្នកស្រី ទេព វន្នី ត្រូវបានរារាំងក្នុងការបំពេញការងារដោយសន្តិវិធី និងមានតម្លៃរបស់ខ្លួនក្នុងនាមជាអ្នកការពារសិទ្ធិមនុស្សជាស្ត្រី។ ការតវ៉ាដោយសន្តិវិធី និងការបញ្ចេញមតិជំទាស់ពុំមែនជាបទល្មើសនោះទេ ហើយអ្នកការពារសិទ្ធិមនុស្សមិនត្រូវរងការផ្តន្ទាទោសព្រហ្មទណ្ឌដោយសារការអនុវត្តសិទ្ធិមនុស្សរបស់ខ្លួនឡើយ។

កញ្ញា សុង ស្រីលាភ សមាជិកសហគមន៍បឹងកក់មានប្រសាសន៍ថា "*ទេព វន្នី ជាស្ត្រីដែលស្អាតស្អំ ហើយគាត់ជាស្ត្រីដែលលះបង់ដ៏មហិមាក្នុងការបំពេញតួនាទីជាពលរដ្ឋ ប៉ុន្តែបែជាត្រូវជាប់ពន្ធនាគាររហូតដល់ទៅបីដង ដោយសារតែប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។ទេព វន្នី ជាសកម្មជនស្ត្រីតែម្នាក់ក្នុងប្រទេសកម្ពុជា ដែលជាប់ពន្ធធនាគារច្រើនដង និងការចាប់ឃុំខ្លួនជាញឹកញាប់។ វាជារឿងអយុត្តិធម៌បំផុតសម្រាប់គាត់ កូនរបស់គាត់ក្លាយជាកូនកំព្រាម្តាយអស់រយៈពេលមួយឆ្នាំ។ ប៉ុន្តែទោះរងការគំរាមគំហែងយ៉ាងណាក៏មិនអាចផ្លាស់ប្តូរឆន្ទៈអ្នកស្រីបានឡើយ។*"

---

[4] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ " សេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការសង្គមក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល" (ថ្ងៃទី០៨ ខែមីនា ឆ្នាំ ១៩៩៩) http://bit.ly/19w8LEm

[5] សេចក្តីសម្រេចមហាសន្និបាតអង្គការសហប្រជាជាតិ " ការលើកកម្ពស់សេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការសង្គម ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល៖ ការការពារអ្នកការពារសិទ្ធិមនុស្សជាស្ត្រី" (ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣) http://bit.ly/19w8LEm

យើងខ្ញុំសូមអំពាវនាវឲ្យអាជ្ញាធរកម្ពុជាលុបចោលនូវការផ្តន្ទាទោសលើអ្នកស្រី ទេព វន្នី ដើម្បីដោះលែងអ្នកស្រីពីពន្ធនាគារ និងបញ្ឈប់រាល់ការយាយី ដែលមានដូចជា ការចាប់ខ្លួន ការចោទប្រកាន់ និងការឃុំខ្លួនមកលើអ្នកស្រី ទេព វន្នី និងសមាជិកនៃសហគមន៍បឹងកក់ដទៃទៀត។

**អង្គការសង្គមស៊ីវិលដែលគាំទ្រសេចក្តីថ្លែងការណ៍រួមនេះមាន ៖**

១. Adil Soz - International Foundation for Protection of Freedom of Speech

២. អង្គការលើកលែងទោសអន្តរជាតិ

៣. អង្គការមាត្រា ១៩

៤. សមាជិកសភាទទួលបន្ទុកសិទ្ធិមនុស្សអាស៊ាន

៥. Association of Caribbean Media Workers

៦. សហគមន៍បឹងប្រាំ

៧. សហគមន៍បឹងឈូក

៨. សហគមន៍ដីធ្លីបឹងកក់

៩. សហគមន៍បឹងត្របែក

១០. អនាគតយុវជនកម្ពុជាអាស៊ាន

១១. សមាគមអភិវឌ្ឍន៍ជីវភាពពលរដ្ឋកម្ពុជា

១២. សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា

១៣. សម្ព័ន្ធសហជីពកម្ពុជា

១៤. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

១៥. បណ្តាញកម្មករធ្វើការងារតាមផ្ទះកម្ពុជា

១៦. សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្ម កម្ពុជា

១៧. សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា

១៨. សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ

១៩. សមាគមកម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធកម្ពុជា

២០. សហភាពការងារកម្ពុជា

២១. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

២២. Canadian Journalists for Free Expression

២៣. Cartoonists Rights Network International

២៤. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស

២៥. Center for Independent Journalism - Romania

២៦. Centro de Reportes Informativos sobre Guatemala - CERIGUA

២៧. Digital Rights Foundation

២៨. អង្គការសមធម៌កម្ពុជា

២៩. សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស (FIDH) ក្នុងក្របខ័ណ្ឌអង្កេតដើម្បីកិច្ចការពារដល់អ្នកការពារសិទ្ធិមនុស្ស

៣០. Foundation for Press Freedom - FLIP

៣១. Free Media Movement

៣២. Freedom Forum

៣៣. អង្គការយេនឌ័រ និងអភិវឌ្ឍន៍នៅកម្ពុជា

៣៤. Globe International Center

៣៥. ក្រុមការងារពិសេសសិទ្ធិលំនៅឋាន

៣៦. Independent Journalism Center - Moldova

៣៧. បណ្តាញព្រះសង្ឃឯករាជ្យដើម្បីយុត្តិធម៌សង្គម

៣៨. យុវជនជនជាតិដើមភាគតិច ឃុំប្រមេ ស្រុកត្បែងមានជ័យខេត្តព្រះវិហារ

៣៩. International Commission of Jurists (ICJ)

៤០. International Press Centre (IPC)

៤១. សមាគម ខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍

៤២. សហគមន៍ជនជាតិដើមភាគតិចគួយ ភូមិព្រះមេរុ ខេត្តព្រះវិហារ

៤៣. សហគមន៍ដីធ្លី ភូមិព្រែកជីក ឃុំដីឌក្រោម ខេត្តកោះកុង

៤៤. សហគមន៍ដីធ្លីភូមិក្រិញ ខេត្តប៉ៃលិន

៤៥. សហគមន៍ដីធ្លី ភូមិស្ពួន ខេត្តសៀមរាប

៤៦. សហគមន៍ដីធ្លីឡពាង ខេត្តកំពង់ឆ្នាំង

៤៧. Media Institute of Southern Africa (MISA)

៤៨. National Union of Somali Journalists (NUSOJ)

៤៩. Norwegian PEN

៥០. PEN American Center

៥១. PEN Canada

៥២. អង្គការពន្លកខ្មែរ

៥៣. សហគមន៍ផ្លូវរថភ្លើងទួលសង្កែ A

៥៤. សហគមន៍ដីធ្លីរាជសីហ៍សាមគ្គីភាព ភូមិរំចេក បាត់ដំបង

៥៥. សមាគមជាងឆ្នោត

៥៦. SFLC.in

៥៧. សហគមន៍ SOS ព្រលានយន្តហោះអន្តរជាតិភ្នំពេញ

៥៨. សម្ព័ន្ធសារព័ត៌មានអាស៊ីអាគ្នេយ៍

៥៩. ក្រុមការងារដើម្បីដោះស្រាយទំនាស់

៦០. បណ្តាញលទ្ធិប្រជាធិបតេយ្យអាស៊ី

៦១. សហព័ន្ធសហជីពកម្មករសំណង់និងព្រៃឈើកម្ពុជា

៦២. Vigilance pour la Démocratie et l'État Civique

៦៣. World Association of Community Radio Broadcasters - AMARC

៦៤. អង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT) ក្នុងក្របខ័ណ្ឌអង្កេតដើម្បីកិច្ចការពារដល់អ្នកការពារសិទ្ធិមនុស្ស